**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

# សេចក្តីបំភ្លឺ
## របស់ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
## អំពី
## ការផ្លាស់ប្តូរមុខតំណែងប្រធានក្រុមប្រឹក្សាភិបាល និង អគ្គនាយក នៃទូរគមនាគមន៍កម្ពុជា

បន្ទាប់ពីមានការផ្លាស់ប្តូរមុខតំណែងប្រធានក្រុមប្រឹក្សាភិបាល និង អគ្គនាយក នៃទូរគមនាគមន៏កម្ពុជា កាលពីថ្ងៃទី ១៨ ខែកុម្ភៈ កន្លងទៅ សារព័ត៌មានមួយចំនួនបានផ្សាយរឿងនេះដោយភ្ជាប់ករណីប្រធានក្រុមប្រឹក្សាភិបាលទៅនឹងកំហុសក្នុងការគ្រប់គ្រងអង្គភាពមួយនេះ ។

ខ្ញុំសូមស្រាយបំភ្លឺករណីនេះ ដូចតទៅ៖

១. ឯកឧត្តម **មាស ប៉ូ** មិនមានពាក់ពន្ធ័នឹងកំហុសខាងលើនោះទេ។ ឯកឧត្តមនៅតែកាន់តំណែងជាអនុរដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងបំពេញការងារតាមការបែងចែកភារកិច្ចរបស់ក្រសួងដដែល។

២. ការដូរប្រធានក្រុមប្រឹក្សាភិបាល ដោយដាក់ឯកឧត្តម **ខូវ មករា** ជំនួសនោះ គឺគ្រាន់ជាការចាប់ដៃគូដែលស័ក្តិសម និងស៊ីគ្នាជាមួយអគ្គនាយកស្តីទី គឺ លោក **សន វី** តែប៉ុណ្ណោះ។

៣. ការស៊ើបអង្កេតដោយក្រុមការងារអគ្គាធិការដ្ឋានរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រុមការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ លើករណីនេះកំពុងបន្តដំណើរការតទៅទៀត។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៨៦
ទូរសារ(៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩